ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១៥៨/២០ អយក.ហវ

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតជាគោលការណ៍ដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០និងឆ្នាំបន្តបន្ទាប់នៅក្រសួងអប់រំ យុវជន និងកីឡា។

**យោង ៖** លិខិតលេខ៨០១៥ សហវ.អថ ចុះថ្ងៃចន្ទ ៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថាៈ កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែងតែចូលរួមសហការជួយសម្របសម្រួលយន្តការនិងនីតិវិធីហិរញ្ញវត្ថុក្នុងការដោះស្រាយបញ្ហាប្រឈមបានជាច្រើន។ ទោះជាយ៉ាងនេះក្តី ក៏នៅមានបញ្ហាប្រឈមខ្លះនៅសេសសល់ក្នុងឆ្នាំចាស់និងកើតថ្មីមិនទាន់បានដោះស្រាយ ជាហេតុធ្វើឱ្យជះឥទ្ធិពលដល់ការអនុវត្តថវិកាឆ្នាំ២០២០និងបណ្តាឆ្នាំខាងមុខ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតគោលការណ៍ពី**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មេត្តាជួយសម្របសម្រួលដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

១-អនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានបើកផ្តល់ប្រាក់អាហារូបករណ៍ជូនសិស្សក្រីក្រជួបការលំបាកនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ដែលកំពុងអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ដោយស្នើសុំកំណត់ក្របខណ្ឌពេលវេលានៃការទម្លាក់ថវិកាចំនួន៣លើកគឺៈ

-លើកទី១ៈនៅដើមខែ វិច្ឆិកា សម្រាប់ត្រីមាសទី៤នៃឆ្នាំថវិកាចាស់(ក្នុងពេលបើកបវេសនកាលដំបូង)

-លើកទី២ៈនៅដើមខែ មីនា សម្រាប់ត្រីមាសទី១នៃឆ្នាំថវិកាថ្មី

-លើកទី៣ៈនៅដើមខែ កក្កដា សម្រាប់ត្រីមាសទី៣នៃឆ្នាំថវិកាថ្មី។ ចំពោះ ការរៀបចំកំណត់រយៈពេលដ៏ជាក់លាក់នេះ ដើម្បីឱ្យស្របជាមួយនឹងសូចនាករគោលដៅនិងក្របខណ្ឌអាហារូបករណ៍ផ្តោតលើគោលការណ៍សមធម៌នៅបឋមសិក្សារបស់ក្រសួងផងដែរ ព្រមទាំងចូលរួមពន្លឿនការបើកប្រាក់អាហារូបករណ៍ជូនសិស្សក្រីក្រជួបការលំបាកឱ្យទាន់ពេលវេលានិងមានស្តង់ដារួមទូទាំងប្រទេស។

(ទំព័រ ១)

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

២-អនុញ្ញាតជាគោលការណ៍ ប្រគល់សិទ្ធិអំណាចបន្ថែមជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ដោយពង្រីកវិសាលភាពបន្ថែមលើប្រកាសលេខ២៧៤ សហវ.ហក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិបើកប្រាក់ សម្រាប់មុខសញ្ញាចំណាយមួយចំនួន ដែលមានគោលរបបច្បាស់លាស់ រួមមាន៖

-ការបើកផ្តល់ប្រាក់អាហារូបករណ៍សម្រាប់ទ្រទ្រង់ជីវភាពនិស្សិតពិការដែលកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលអន្តេវាសិកនិងកំពុងសិក្សាកម្រិតឧត្តមសិក្សានៅរាជធានីភ្នំពេញ ដែលអនុវត្តតាមស្មារតីនៃលិខិតលេខ២៤៦៦ សហវ.អថ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពន្លឿនការអនុវត្តថវិកាឱ្យស្របតាមផែនការសកម្មភាពនិងសូចនាករគោលដៅគន្លឹះរបស់ក្រសួង

-ការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ដែលកំពុងអនុវត្តតាមស្មារតីនៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចូលរួមពន្លឿនការអនុវត្តថវិកាឱ្យឆ្លើយតបទៅនឹងក្របខណ្ឌពេលវេលានិងផែនការសកម្មភាពប្រចាំឆ្នាំដែលបានគ្រោងទុក។

៣-អនុញ្ញាតជាគោលការណ៍ ឱ្យសាលាគរុកោសល្យនិងវិក្រឹតការខេត្តនិងមជ្ឈមណ្ឌលគរុកោសល្យខេត្ត បានប្រើប្រាស់អនុគណនីចំនួន៤(បួន) សម្រាប់អនុវត្តក្នុងក្របខណ្ឌថវិកាដំណើរការគ្រឹះស្ថានសាមីដែលអនុវត្តតាមលំនាំមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF) ហើយស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាគឺ៖

-ជំពូក៦០(ការទិញ)៖ ចំនួនពីរគឺអនុគណនី៦០០២៨(សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ)និងអនុគណនី៦០០៥៨(សម្ភារតូចតាច សង្ហារិម និងសម្ភារបរិក្ខារផ្សេងៗ)

-ជំពូក៦១(សេវាកម្ម)៖ ចំនួនពីរគឺអនុគណនី៦១០៥៨ (ការថែទាំនិងជួសជុលផ្សេងៗ) និងអនុគណនី៦១១០៨ (ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ)។

៤-អនុញ្ញាតជាគោលការណ៍ ឱ្យវិទ្យាល័យអប់រំពិសេស បានប្រើប្រាស់អនុគណនីចំនួន៤(បួន)ត្រង់ចំណុចទី៣ខាងលើ ដែលបានផ្តល់ថវិកាចំនួន ៦០ ០០០ ០០០រៀល (ហុកសិបលានរៀលគត់)/សាលា/ឆ្នាំ សម្រាប់ចំណាយក្នុងកិច្ចដំណើរការសាលារៀនសាមី ហើយជាពិសេសពាក់ព័ន្ធនឹងសម្ភាររៀននិងបង្រៀនក្នុងគោលបំណងចូលរួមចំណែកលើកកម្ពស់សេវាអប់រំប្រកបដោយសមធម៌និងបរិយាបន្ន។

៥-អនុញ្ញាតជាគោលការណ៍ ឱ្យគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលអនុវត្តកម្មវិធីបង្រៀននិងរៀនពេញមួយថ្ងៃ បានប្រើប្រាស់អនុគណនីចំនួន៤(បួន) ត្រង់ចំណុចទី៣ខាងលើ ដែលបានផ្តល់ថវិកាចំនួន ២០ ០០០ ០០០រៀល(ម្ភៃលានរៀលគត់)/សាលា/ឆ្នាំ ដើម្បីចូលរួមគាំទ្រការចំណាយកិច្ចដំណើរការរដ្ឋបាលធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងការអភិវឌ្ឍធនធានមនុស្សនាយុគសម័យបច្ចុប្បន្ន។

៦-អនុញ្ញាតជាគោលការណ៍ ឱ្យមជ្ឈមណ្ឌលសិក្សាសហគមន៍ បានប្រើប្រាស់នូវចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាគឺជំពូក៦២(អត្ថប្រយោជន៍សង្គម) គណនី៦២០២(ជំនួយសង្គមដល់ប្រជាពលរដ្ឋ) អនុគណនី

៦២០២៨(ជំនួយសង្គមផ្សេងៗ) សម្រាប់ការផ្តល់ប្រាក់លើកទឹកចិត្តជូនដល់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលមានសមាសភាពយ៉ាងច្រើន៥(ប្រាំ)រូប ដើម្បីបំពេញការងារដឹកនាំនិងគ្រប់គ្រងមជ្ឈមណ្ឌល ដោយបានផ្តល់ជូនចំនួន១០០ ០០០រៀល(មួយរយពាន់រៀល)/ម្នាក់/ខែ ហើយស្របតាមស្មារតីនៃអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ រីឯការកំណត់ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាសម្រាប់មុខសញ្ញាចំណាយនេះ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវនិងប្រាកដប្រជា ព្រមទាំងឱ្យមានស្តង់ដារួម។

៧-អនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកទទួលបន្ទុករៀបចំការគ្រោងថវិកាប្រចាំឆ្នាំសម្រាប់ចំណាយវិនិយោគ(ជំពូក២១) ដូចលំនាំនៃចំណាយចរន្ត ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងត្រួតពិនិត្យនិងជ្រើសរើសគម្រោងអាទិភាពឱ្យចំទិសដៅ ព្រមទាំងឱ្យមានសង្គតិភាពទៅនឹងតម្រូវការជាក់ស្តែងរបស់ក្រសួង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពជួយដោះស្រាយបញ្ហាប្រឈមខាងលើ ជូនក្រសួងអប់រំ យុវជន និងកីឡា ទាន់ពេលវេលា ដើម្បីសម្រួលដល់ការអនុវត្តថវិកាក្នុងឆ្នាំ២០២០និងបណ្តាឆ្នាំខាងមុខ ឱ្យប្រព្រឹត្តទៅប្រកបដោយភាពច្បាស់លាស់ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃ ចន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**

-អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-កាលប្បវត្តិ

-ឯកសារ .នាយកដ្ឋានហិរញ្ញវត្ថុ